ដោះស្រាយវិវាទការងារ

# ព្រឹត្តិប័ត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងការកាត់សេចក្តី ដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច

ឧសភា ២០១១

## ការដោះស្រាយវិវាទការងារដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងខែឧសភា ឆ្នាំ ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងវិវាទការងារចំនួន ៨ ដែលនៅក្នុងនោះមាន សំណុំរឿង ៣ គ្របដណ្តប់ដោយ MoU ។

ជាសរុប ពីខែមករា ដល់ខែឧសភា ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលសំណុំរឿងវិវាទការងារចំនួន ៦១ ដែលនៅក្នុងនោះមានសំណុំរឿង ៣៥ គ្របដណ្តប់ដោយ MoU ។ តារាងខាងក្រោមបង្ហាញពីចំនួនសំណុំរឿងសរុបដែលក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលបានដោយបែងចែកជាសំណុំរឿងគ្របដណ្តប់ដោយ MoU និងសំណុំរឿងមិនគ្របដណ្តប់ដោយ MoU និងលទ្ធផលជារួមអំពីការដោះស្រាយវិវាទការងារ ។

ចំនួនសំណុំរឿងដែលទទួលបាន ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល

( មករា - ឧសភា)



# ការសង្កេតលើការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលកាត់សេចក្ដីដោយអាជ្ញាកណ្ដាលចងការតព្វកិច្ច

នៅក្នុងខែមេសា មានសំណុំរឿងចំនួន ៤ បានចុះបញ្ជី ហើយដំណើរការសំណុំរឿងទាំងនេះ បានអូសបន្លាយរហូតដល់ខែឧសភា។ មានសំណុំរឿង ២ ភាគីបានឈានដល់កិច្ចព្រមព្រៀងនៅក្នុងសវនការ និងមានសំណុំរឿង ១ ភាគីសម្រេចបានកិច្ចព្រមព្រៀង នៅមុនពេលសវនាការ។ មានតែសំណុំរឿងប៉ុណ្ណោះ បានត្រូវសម្រេចសេចក្ដីដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

នៅក្នុងខែឧសភា មានសំណុំរឿង ២ បានចុះបញ្ជី និងមានសវនការ។ ក្នុងចំណោមសំណុំរឿងចំនួន ៥ ដែលមានសវនការនៅក្នុងខែឧសភានេះ យើងបានសង្កេតឃើញថា:

១. ការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈ

- នៅក្នុងសំណុំរឿង ៤ ភាគីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីអាជ្ញាកណ្ដាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ។
- នៅក្នុងសំណុំរឿង ១ ភាគីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីអាជ្ញាកណ្ដាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ និងវិវាទអំពីផលប្រយោជន៍។
- នៅក្នុងសំណុំរឿង ៥ ភាគីយល់អំពីបទប្បញ្ញត្តិរបស់ MoU ជាពិសេសទាក់ទងនឹងអាជ្ញាកណ្ដាលជាប់កាតព្វកិច្ចលើ វិវាទអំពីសិទ្ធិ និងបទប្បញ្ញត្តិមិនធ្វើកូដកម្ម។
- នៅក្នុងសំណុំរឿង ៤ ភាគីរៀបចំបានល្អក្នុងការបង្ហាញឯកសារ ឬភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។
- នៅក្នុងសំណុំរឿង ៥ ភាគីបានចូលរួមយ៉ាងសកម្មនៅក្នុងសវនការ តាមរយៈការបង្ហាញអង្គហេតុ និងភស្តុតាងបានល្អ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន។
- នៅក្នុងសំណុំរឿង ៤ ភាគីបង្ហាញឆន្ទៈរបស់ខ្លួន ដើម្បីដោះស្រាយវិវាទតាមរយៈកិច្ចព្រមព្រៀង។
- នៅក្នុងសំណុំរឿង ៥ ភាគីមានវត្តមាននៅក្នុងសវនការ។
- នៅក្នុងសំណុំរឿង ៥ ភាគីមិនបានធ្វើកូដកម្មទេ។

២. បញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

- នៅក្នុងសំណុំរឿង ១ និយោជកមិនបានបង្ហាញឆន្ទៈរបស់ខ្លួន ដើម្បីដោះស្រាយវិវាទ តាមរយៈការចុះកិច្ចព្រមព្រៀងមួយ ជាមួយកម្មករនិយោជិតទេ។ និយោជកទទួចឱ្យកម្មករនិយោជក គោរពតាមបទបញ្ជាផ្ទៃក្នុង។
- នៅក្នុងសំណុំរឿង ១ ភាគីមិនបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងស្ដីពីអាជ្ញាកណ្ដាលជាប់កាតព្វកិច្ច លើវិវាទអំពីសិទ្ធិ ពីព្រោះនិយោជកគិតថាកម្មករនិយោជិតនឹងនៅតែធ្វើកូដកម្ម។
- នៅក្នុងសំណុំរឿង ១ ភាគីមិនបានរៀបចំឱ្យបានល្អក្នុងការបង្ហាញឯកសារ ឬភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។
- នៅក្នុងសំណុំរឿង ១ កម្មករនិយោជិតមិនបានរៀបចំឱ្យបានល្អ ក្នុងការបង្ហាញឯកសារ ឬភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។



មន្ត្រីលេខាធិការដ្ឋានពន្យល់ភាគី អំពីដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=

អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
ដើម្បីឈប់ទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ
dvandeth@arbitrationcouncil.org ជាមួយប្រធានបទ“Unsubscribe – The AC E-Newsletter”.

អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
ដើម្បីទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ
dvandeth@arbitrationcouncil.org ជាមួយប្រធានបទ “Subscribe – The AC E-Newsletter”.

+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=

ផ្ទះលេខ៧២ ផ្លូវ៥៩២ កែង ផ្លូវលេខ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក
ទូរស័ព្ទ: ៨៥៥ ២៣ ៨៨១ ៨១៤
ទូរសារ: ៨៥៥ ២៣ ៨៨១ ៩១៨
អ៊ីម៉ែល info@arbitrationcouncil.org
វែបសាយ www.arbitrationcouncil.org